ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍

លេខ ៤១៦ សដណ.អគ១

ថ្ងៃ ចន្ទ ៤ រោច ខែ អស្សុជ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសបេក្ខជន បេក្ខនារី ចូលរៀនវគ្គបណ្តុះបណ្តាលវិក្រឹត្យការលើជំនាញស្ប៉ា និងសុខុមាលភាពកម្ពុជា

ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ សហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (ASEAN-Japan Center) មានកិត្តិយសសូមជូនដំណឹងដល់ **លោក លោកស្រី នាងកញ្ញា** ជាអ្នកជំនាញស្ប៉ា ដែលកំពុងបម្រើការងារផ្នែកស្ប៉ានៅតាមសណ្ឋាគារ និងអាជីវកម្មស្ប៉ា ឲ្យបានជ្រាបថា៖ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តផែនការស្តារឡើងវិញនៃវិស័យទេសចរណ៍ ក្រោយវិបត្តិកូវីដ-១៩ ក៏ដូចជាពង្រឹង និងបង្កើនសមត្ថភាព បុគ្គលិកបម្រើការងារជំនាញស្ប៉ា និងសុខុមាលភាព ឲ្យទទួលបានគុណវុឌ្ឍិស្របតាមយន្តការអាស៊ាន (MRA) និងដើម្បីត្រៀមបើកទទួលទេសចរសុវត្ថិភាពនាពេលខាងមុខគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ សូមប្រកាសជ្រើសរើសបេក្ខជន បេក្ខនារីទាំងពីរភេទ ចូលរួមវគ្គបណ្តុះបណ្តាលវិក្រឹត្យការលើជំនាញស្ប៉ា និងសុខុមាលភាពកម្ពុជា (Upskill Spa Professionals) ដោយឥតគិតថ្លៃតាមកាលបរិច្ឆេទដូចខាងក្រោម៖

**- កាលបរិច្ឆេទសិក្សា ចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១**

**(រយៈពេល២០ថ្ងៃ ពីថ្ងៃចន្ទ - សុក្រ ១ថ្ងៃសិក្សា ៣ម៉ោង)**

**- ក្រុមទី១៖ វេនព្រឹក ចាប់ពីម៉ោង ៨:៣០ នាទីព្រឹក - ១១:៣០ នាទីព្រឹក**

**- ក្រុមទី២៖ វេនរសៀល ចាប់ពីថ្ងៃម៉ោង ១៣:០០នាទីរសៀល - ១៦:០០នាទីរសៀល**

**១. <u>លក្ខខណ្ឌជ្រើសរើស</u> ÷**

– មានបទពិសោធន៍ផ្នែកស្ប៉ា និងសុខុមាលភាព (អ្នកជំនាញម៉ាស្សា និងស្ប៉ា) យ៉ាងតិច ០៣ឆ្នាំ ព្រមទាំងមានចំណេះដឹងភាសាអង់គ្លេសកម្រិតមូលដ្ឋានជាអាទិភាព

– បេក្ខជន បេក្ខនារីទាំងពីរភេទ ត្រូវមានការបញ្ជាក់ជាបុគ្គលិកកំពុងបម្រើការងារពីអង្គភាពរបស់ខ្លួន

– បេក្ខជន បេក្ខនារីទាំងពីរភេទ ត្រូវមានកាតបញ្ជាក់បានចាក់វ៉ាក់សាំងបង្ការកូវីដ-១៩ បានពេញលេញ។

**២. <u>អត្ថប្រយោជន៍</u> ÷**

– បេក្ខជន បេក្ខនារីទាំងពីរភេទ នឹងទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពពីក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

– ទទួលបានការបង្ហាត់បង្រៀនជំនាញស្ប៉ា-ម៉ាស្សាដោយផ្ទាល់ពីគ្រូអន្តរជាតិដែលមានបទពិសោធន៍ផ្នែកស្ប៉ាជាង៣០ឆ្នាំ គ្រូផ្នែកសរីរៈវិទ្យា និងគ្រូផ្នែកបដិសណ្ឋារកិច្ចដែលមានបទពិសោធន៍ខ្ពស់។

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ:+ ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

- បង្កើនចំណេះដឹងមូលដ្ឋាន និងជំនាញ លើផ្នែកបដិសណ្ឋារកិច្ច កាយវិភាគវិទ្យា និងសរីរៈវិទ្យា បច្ចេកទេសម៉ាស្សាដងខ្លួន ម៉ាស្សាបាតជើង ការស្អំដោយប្រើឱសថបូរាណ ខាត់ស្បែក ការប្រើប្រាស់ផលិតផលធម្មជាតិ ការចែករំលែកចំណេះដឹងពីឧស្សាហកម្មស្ប៉ានៅប្រទេសជប៉ុន ដោយអ្នកជំនាញជនជាតិជប៉ុន និងទស្សនកិច្ចសិក្សានៅទីតាំងស្ប៉ាមួយចំនួននៅរាជធានីភ្នំពេញ។

៣. <u>**ភារកិច្ចរបស់បេក្ខជន បេក្ខនារី អំឡុងពេលសិក្សា**</u> ÷

- ត្រូវបង្ហាញកាតចាក់វ៉ាក់សាំងការពារកូវីដ-១៩ មុនពេលចូលថ្នាក់រៀនថ្ងៃដំបូង
- ត្រូវពាក់ម៉ាសជានិច្ច និងត្រូវលាងដៃជាមួយទឹកសម្លាប់មេរោគជាប្រចាំ
- ត្រូវវាស់កម្ដៅមុនពេលចូលថ្នាក់រៀន និងរក្សាគម្លាតសង្គមជានិច្ចក្នុងអំឡុងពេលសិក្សា
- ត្រូវចូលរួមដោយយកចិត្តទុកដាក់តាមការណែនាំរបស់ក្រសួងសុខាភិបាលតាមរយៈការអនុវត្ត ៣កុំ ៣ការពាររបស់រាជរដ្ឋាភិបាលកម្ពុជា
- ត្រូវអនុវត្តតាមនីតិវិធីប្រតិបត្តិស្ដង់ដានានាដែលដាក់ចុះដោយក្រសួងទេសចរណ៍

៤. <u>**កាលបរិច្ឆេទទទួលពាក្យ**</u> ÷

- កាលបរិច្ឆេទឈប់ទទួលពាក្យ **ត្រឹមថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១**
- បេក្ខជន បេក្ខនារីទាំងពីរភេទ ដែលមានចំណាប់អារម្មណ៍ លើវគ្គបណ្ដុះបណ្ដាលខាងលើអាចចុះឈ្មោះជាបឋមតាមពាក្យស្នើសុំ តាមរយៈប្រព័ន្ធ QR Code ខាងក្រោម។
- បេក្ខជន បេក្ខនារីទាំងពីរភេទ អាចផ្ញើពាក្យស្នើសុំចូលរួមវគ្គបណ្ដុះបណ្ដាលតាមរយៈតេឡេក្រាមលេខ ០១៦ ២៣០ ៧៨៩/ ០៨៧ ៦៩ ៦៩ ១១ឬអាសយដ្ឋានអ៊ីម៉ែល chanleakhena_sim29@yahoo.com ។
- <u>**ព័ត៌មានបន្ថែមសូមទាក់ទង**</u> ៖
  - លេខាធិការដ្ឋាន គ.ជ.អ.ទ. នៃក្រសួងទេសចរណ៍ ៖ ០១៦ ២៣០ ៧៨៩។

<u>**កំណត់សម្គាល់**</u>៖

ចំពោះបេក្ខជន បេក្ខនារី ដែលបានបំពេញតាមលក្ខខណ្ឌខាងលើ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ នឹងជូនដំណឹងពីការចូលរួម មុនការចាប់ផ្ដើមវគ្គបណ្ដុះបណ្ដាល។

**ក្រសួងទេសចរណ៍**

<u>**ចម្លងជូន**</u>៖
- គ្រប់នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងទេសចរណ៍
- មន្ទីរទេសចរណ៍រាជធានីភ្នំពេញ
- សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈទេសចរណ៍
- សហព័ន្ធទេសចរណ៍កម្ពុជា
- សមាគមសណ្ឋាគារកម្ពុជា
- ឯកសារ-កាលប្បវត្តិ